10/05

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

-សំណុំរឿងព្រហ្មទណ្ឌ លេខ ១៧៨៩
ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៨
-សាលក្រម លេខ ៥៦ ក្រ.២ ´ យ´
ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១០

# តាងនាមប្រជារាស្ត្រខ្មែរ

**សាលាដំបូងរាជធានីភ្នំពេញ** បើកសវនាការជាសាធារណៈ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១០ ជំនុំជំរះលើសំនុំរឿងព្រហ្មទណ្ឌ លេខ ១៧៨៩ ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៨ ដោយមានសមាសភាព ចូលរួមដូចតទៅ :

**ក្រុមប្រឹក្សាជំនុំជំរះ**

-លោក [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**ដើម្បីជំនុំជំរះ** សំណុំរឿងព្រហ្មទណ្ឌ លេខ ១៧៨៩ ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៨ ទាក់ទងទៅនិងបណ្តឹងទាស់ លេខ ៦៧ ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១០ ដែលមានជនជាប់ចោទ :

ឈ្មោះ [redacted] ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ កើតនៅភូមិទី៣ សង្កាត់ច្បារអំពៅ ខណ្ឌឫស្សីកែវ មានទីលំនៅផ្ទះលេខ ១២០៣ ផ្លូវលេខ ៥ ក្រុមទី៥ ភូមិទី២ សង្កាត់ច្រាំងចំរេះ ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ ស្មាន មូសា ´ ស ´ ម្តាយឈ្មោះ លី វី ´ រ ´ ទោសពីមុនគ្មាន ។

ត្រូវជាប់ចោទពីបទ **ប្លន់ ´** លួចមានគ្នាច្រើន ´ ប្រព្រឹត្តនៅ សង្កាត់ច្រាំងចំរេះ ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨ ដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ ។

-ដើមបណ្តឹងឈ្មោះ [redacted] ភេទប្រុស អាយុ៤២ឆ្នាំ មានទីលំនៅផ្ទះលេខ ៣១៦ ផ្លូវជាតិលេខ ៥ ក្រុមទី១ ភូមិទី២ សង្កាត់ច្រាំងចំរេះទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

-មេធាវី លោក [redacted] ការពារជនជាប់ចោទឈ្មោះ [redacted]

**ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ :**

-កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨ នៅវេលាម៉ោង ២១ និង៤៥ នាទី នៅចំនុចផ្ទះលេខ ៣១៦ ផ្លូវលេខ ៥ ក្រុមទី១ ភូមិទី២ សង្កាត់ច្រាំងចំរេះទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ នៅពេលដើមបណ្តឹងឈ្មោះ [redacted] ទៅសូត្រធម៌នៅវិហារ ទុកប្រពន្ធ កូន សំរាកនៅផ្ទះ ដោយចាក់សោរមិនបានដកហូតកូនសោរ



Scanned by CamScanner

នៅពេលនោះ មានមនុស្សមួយក្រុម មានឈ្មោ[redacted]ឈ្មោះ [redacted] បានលូកដៃតាមចន្លោះទ្វារ ចាក់សោរទ្វារដែលម្ចាស់ភ្លេចដកកូនសោរទុក ហើយចាក់ចូលក្នុងផ្ទះ បានលួចយកទូរសព្ទ័ដៃម៉ាកណូគាចំនួនមួយគ្រឿង និងដោះយកខ្សែកផ្លាកទីន មួយខ្សែពីកូនដើមបណ្តឹងកំពុងតែដេក ពេលនោះកូនដើមបណ្តឹងបានភ្ញាក់ដឹងខ្លួន ហើយស្គាល់ជនត្រូវចោទម្នាក់ ឈ្មោះ[redacted]ហើយ បានប្រាប់ទៅដើមបណ្តឹងដែលជាឪពុក ។ លុះដល់ថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០០៨ ដើមបណ្តឹងបានចាប់ និងនាំឈ្មោ[redacted]សមត្ថកិច្ចតែម្តង ។

-បានឃើញ ពាក្យបណ្តឹងរបស់ឈ្មោះ [redacted]ុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៨

-បានឃើញ កំណត់ហេតុប្រគល់ ទទួលជនល្មើស ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០០៨ របស់អធិការដ្ឋាននគរបាលខណ្ឌឫស្សីកែវ

-បានឃើញ កំណត់ហេតុសាកសួរបំភ្លឺរបស់ឈ្មោ[redacted]ុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០០៨ នៅអធិការដ្ឋាននគរបាលខណ្ឌឫស្សីកែវ

-បានឃើញ កំណត់ហេតុសួរចម្លើយជនល្មើសឈ្មោ[redacted]ះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៨ នៅអធិការដ្ឋាននគរបាលខណ្ឌឫស្សីកែវ

-បានឃើញ របាយការណ៍សំយោគលេខ ២៩៣/០៨ ចុះថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ២០០៨ របស់អធិការដ្ឋាននគរបាល ខណ្ឌឫស្សីកែវ

-បានឃើញ កំណត់ហេតុសួរចម្លើយជនជាប់ចោទឈ្មោះ[redacted]ទី២៨ ខែកញ្ញា ឆ្នាំ២០០៨ របស់អយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ កំណត់ហេតុសួរចម្លើយជនជាប់ចោទឈ្មោ[redacted]ថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៨ របស់ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ កំណត់ហេតុសួរយកចម្លើយដើមបណ្តឹងឈ្មោះ [redacted]ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ របស់ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ១៣០៩ អយ.ខ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៩ របស់តំណាងអយ្យការអម សាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជំរះ លេខ ១១៤៦១ តព្រ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ របស់ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជំរះ លេខ ៥១៥ តព្រ ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៨ របស់ប្រធានសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌ លេខ ១៩៦ ក្រ.២ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ បណ្តឹងទាស់លេខ ៦៧ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០ របស់ជនជាប់ចោទឈ្មោះ[redacted]

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted]ានឆ្លើយថា ខ្លួនត្រូវសមត្ថកិច្ចចាប់ នៅថ្ងៃទី ២៦ ខែមករា ឆ្នាំ២០១០ ដោយគេកាត់ទោសកំបាំងមុខ ដោយសារពាក់ពន្ធ័និងឈ្មោះ [redacted] ។ ដំបូងឡើយ ខ្លួន



Scanned by CamScanner

ជិះម៉ូតូទៅរកឈ្មោ[redacted]ដែលជាមិត្តភ័ក្រ ហើយពេលនោះខ្លួនបានជួបពេ[redacted]ាមផ្លូវ ហើយវាក៏ឱ្យខ្លួនជូនវាទៅលក់របស់ ខ្លួនមិនដឹងថា ពួកវាទៅយករបស់គេទេ ខ្លួនគ្រាន់តែបានទៅហូបចុកជាមួយវា ។ ខ្លួនពុំបានសួរនាំពួកវាទេ នៅយប់នោះខ្លួនហូបចុកមានគ្នាចំនួនប្រាំមួយនាក់ ពួកខ្លួនបានផឹកស៊ីនៅផ្ទះឈ្មោះ [redacted]ពេលដែលពួកវាយករបស់គេហើយ ។

-សាក្សីឈ្មោះ[redacted]ានឆ្លើយថា នៅពេលយប់វេលាម៉ោងប្រហែលប្រាំបីទៅម៉ោងប្រាំបួនយប់ ខ្លួនបានឃើញផ្ទះមួយ បិទទ្វារអត់ចាក់សោរ ហើយខ្លួនក៏លូកដៃតាមប្រឡោះទ្វារនេះ បើកទ្វារចូលយកខ្សែក និងទូរសព្ទ័គេ ខ្លួនមិនស្គាល់ជនរងគ្រោះទេ ខ្លួនចូលយកតែម្នាក់ខ្លួនទេ ប៉ុន្តែមានឈ្មោ[redacted]ឈ្មោះ [redacted]នៅអង្គុយលេងក្បែរនោះ ។ ចំពោះឈ្មោ[redacted]ពុំនៅកន្លែងកើតហេតុទេ ។ ពេលខ្លួនយករបស់គេហើយ អ្នកអង្គុយលេងខាងក្រៅពុំបានរត់ទេ ក្រោយមកបានទៅជាមួយខ្លួន ដោយអ្នកខ្លះដើរ អ្នកខ្លះជិះម៉ូតូ ។ ខ្លួនបានជួបឈ្មោះ[redacted]នៅពេលខ្លួនយករបស់គេបានហើយ និងបានជួបឈ្មោះនេះនៅតាមផ្លូវគាត់កំពុងជិះម៉ូតូម្នាក់ឯង ។ ពេលខ្លួនចូលទៅយករបស់គេ ពុំមានអ្នកណាបានដឹងទេ ព្រោះពួកគេអង្គុយលេងនៅខាងក្រៅទេ ពេលដែលខ្លួនបង្ហាញរបស់នោះ ទើបពួកគេបានដឹង ។ អ្នកអង្គុយលេងខាងក្រៅពុំមានឈ្មោ[redacted]

-ប្រធានក្រុមប្រឹក្សាជំនុំជំរះ បានឱ្យក្រឡាបញ្ជី អានឯកសារចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី.ចម្លើយសាក្សី និងរបាយការណ៍ស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌ ។

-តំណាងអយ្យការ បានធ្វើសេចក្តីសន្និដ្ឋានថា ជនជាប់ចោទបានឆ្លើយថា ខ្លួនពុំពាក់ពន្ធ័និងអំពើប្រព្រឹត្តរបស់ឈ្មោ[redacted]ពុំបានដឹងថាឈ្មោះនេះ និងបក្សពួកយករបស់គេទេ ខ្លួនគ្រាន់តែបានជិះម៉ូតូទៅរកមិត្តភ័ក្រឈ្មោះ[redacted]ហើយបានជួបឈ្មោ[redacted]នៅតាមផ្លូវ និងបានជូនទៅលក់របស់ ហើយបានហូបចុកជាមួយពួកគេ ឯសាក្សីឈ្មោះ[redacted]ដែលជាអ្នកប្រព្រឹត្តផ្ទាល់ ហើយត្រូវបានជំនុំជំរះហើយនោះ បានឆ្លើយថា បានជួបឈ្មោះ [redacted]នៅតាមផ្លូវកំពុងជិះម៉ូតូ ក្រោយពេលយករបស់គេបានហើយ ដោយបញ្ជាក់ថា ឈ្មោះ[redacted]បានដឹងពីរឿងហេតុខាងលើ គឺជាការប្រកែកដោះសារ ដើម្បីឱ្យបក្សពួករួចខ្លួន ។ ភស្តុតាងនៅក្នុងរឿងនេះ គឺជាចម្លើយរបស់ឈ្មោ[redacted]លបានឆ្លើយនៅដំណាក់កាលស៊ើបសួរ.នៅសមត្ថកិច្ចនគរបាល និងវត្ថុតាងដែលដកហូតបាន ។ តំណាងអយ្យការ សុំតំកល់ការចោទប្រកាន់នៅដដែល និងសុំឱ្យតុលាការផ្តន្ទាទោសតាមច្បាប់ ។

-មេធាវីការពារជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា តាមចម្លើយរបស់ដើមបណ្តឹង បានបញ្ជាក់ថា ខ្លួនពុំនៅផ្ទះ ពេលនោះខ្លួនទៅសូត្រធម៌ រឿងហេតុកូននិយាយប្រាប់ ហើយចម្លើយរបស់កូនក្តីខ្លួនឈ្មោះ[redacted]បានបញ្ជាក់ថា ពុំបានដឹងឈ្មោះ[redacted]ងបក្សពួកយករបស់គេទេ ខ្លួនគ្រាន់តែបានជួបនៅតាមផ្លូវ.បានជូនគេទៅលក់របស់ដែលគេបានហើយនោះ ដោយមិនដឹងថា គេបានមកពីណាឡើយ និងបានហូបចុកជាមួយគេប៉ុណ្ណោះ ហើយម្យ៉ាងទៀត សាក្សីដែលនៅចំពោះមុខអង្គសវនាការនេះ ដែលជាអ្នកប្រព្រឹត្តផ្ទាល់ និងបានដឹងរឿងហេតុទាំងអស់នៅថ្ងៃកើតហេតុ បានបញ្ជាក់ជូនតុលាការថា កូនក្តីខ្លួនពុំបានអង្គុយលេងនៅខាងក្រៅផ្ទះកន្លែងកើតហេតុទេ គឺបានជួបនៅតាមផ្លូវដោយចៃដន្យនៅពេលដែលខ្លួនបានយករបស់គេហើយ នេះបង្ហាញឱ្យឃើញថា កូនក្តីខ្លួនពុំបានប្រព្រឹត្តអំពើ **ប្លន់** ដូចការចោទប្រកាន់របស់តំណាងអយ្យការឡើយ ខ្លួនសុំឱ្យតុលាការលើកលែងចោទប្រកាន់ដល់កូនក្តីខ្លួន និងសុំបដិសេធសាលក្រមមុនចោល សាលក្រមលេខ ១៥៦ "ក្រ.២" ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។



Scanned by CamScanner

-ជនជាប់ចោទឈ្មោះ[redacted]ឆ្លើយសំដីចុងក្រោយថា ខ្លួនសុំឱ្យតុលាការ លើកលែងទោសដល់ខ្លួន និងសុំបដិសេធការកាត់ទោសដាក់គុកខ្លួនចំនួនប្រាំឆ្នាំដោយសាលក្រមកំបាំងមុខនោះ ។

## សាលាដំបូងរាជធានីភ្នំពេញ

## យល់ឃើញថា

-ចម្លើយជនជាប់ចោទឈ្មោះ[redacted]នាពេលសវនាការបានឆ្លើយថា មិនបានដឹងរឿងហេតុអំពីការប្លន់យកទ្រព្យសម្បត្តិរបស់ជនរងគ្រោះ និងបដិសេធសាលក្រមកំបាំងមុខលេខ ១៥៦ ក្រ.២ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានផ្តន្ទាទោសខ្លួនចំនួនប្រាំឆ្នាំ និងសំណូមពរសុំឱ្យតុលាការ លើកលែងចោទប្រកាន់ខ្លួន ដោយអះអាងថា គ្រាន់តែបានជួបជនជាប់ចោទឈ្មោះ[redacted]តាមផ្លូវដោយចៃដន្យ បានជូនទៅលក់របស់ មិនដឹងថាគេបានមកពីណា និងថា គ្រាន់តែបានជិកស៊ីនៅផ្ទះឈ្មោះ[redacted]ពេលដែលបក្សពួកយក របស់គេបានហើយ ជាការឆ្លើយដោះសារ គ្មានភស្តុតាងត្រឹមត្រូវតាមច្បាប់ មិនអាចឱ្យពិចារណាបានឡើយ ព្រោះថាឈ្មោះ[redacted]ដែលជាបក្សពួកបានឆ្លើយសារភាពនៅចំពោះមុខនគរបាលយុត្តិធម៌ ថា ខ្លួនជាអ្នកចូលទៅលួច បក្សពួករបស់ខ្លួនឈ្មោះ[redacted]ចាំខាងក្រៅដើម្បីមើលផ្លូវ នៅពេលយកបានទ្រព្យសម្បត្តិជនរងគ្រោះ ហើយប្រគល់ទៅឱ្យឈ្មោះ[redacted]និង[redacted]ជាអ្នកលក់ ដូចនេះអាចកំណត់បានថា ជនទាំងនេះជាសហចារី រួមគ្នាចូលលួចទ្រព្យសម្បត្តអ្នកដ៏ទៃជាប្រាកដ មិនអាចប្រកែកបានឡើយ គប្បីសំរេចដកល់សាលក្រមកំបាំងមុខលេខ ១៥៦ ក្រ.២ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកនៅដដែល និងបដិសេធសំណូមពរស្នើសុំរបស់ជនជាប់ចោទឈ្មោះ[redacted]តាមច្បាប់ ។

-ចម្លើយសាក្សីឈ្មោះ[redacted]ដែលជាពិរុទ្ធជនបានឆ្លើយ នៅពេលសវនាការថា នៅថ្ងៃកើតហេតុខ្លួនបានឃើញផ្ទះមួយបិទទ្វារអត់ចាក់សោរ ហើយខ្លួនក៏លូកដៃតាមប្រឡោះទ្វារ បើកទ្វារចូលយកខ្សែក និងទូរសព្ទ័គេ ដោយចូលទៅតែម្នាក់ឯង ប៉ុន្តែមានឈ្មោះ[redacted]ឈ្មោះ[redacted]ឈ្មោះ[redacted]នៅអង្គុយលេងក្បែនោះ ឈ្មោះ[redacted]នៅកន្លែងកើតហេតុទេ ពេលខ្លួនយករបស់គេហើយ អ្នកដែលអង្គុយលេងខាងក្រៅពុំបានរត់ទេ ក្រោយមកបានទៅជាមួយខ្លួន ដោយអ្នកខ្លះដើរ អ្នកខ្លះជិះម៉ូតូ និងបានបញ្ជាក់ថា បានជួបឈ្មោះ[redacted]ពេលខ្លួនយករបស់គេបានហើយ តាមផ្លូវពេលឈ្មោះនេះកំពុងជិះម៉ូតូម្នាក់ឯង និងថាខ្លួនចូលទៅយករបស់គេ ពុំមានអ្នកណាដឹង ពួកគេអង្គុយលេងនៅខាងក្រៅ ពេលដែលខ្លួនបង្ហាញរបស់នោះ ទើបពួកគេបានដឹង គឺជាការផ្តល់ចម្លើយដោះសារ ដើម្បីឱ្យបក្សពួកខ្លួន ឈ្មោះ[redacted]រួចផុតពីការទទួលខុសត្រូវ ជាចម្លើយដែលមានភាពខុសគ្នាទៅនិងចម្លើយដែលបានឆ្លើយនៅចំពោះមុខនគរបាលយុត្តិធម៌ និងចៅក្រមស៊ើបសួរ ជាចម្លើយមិនសមហេតុផលត្រឹមត្រូវតាមច្បាប់ មិនអាចឱ្យពិចារណាបានឡើយ ។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ បានសន្និដ្ឋានបញ្ជាក់ពីភស្តុតាងដាក់បន្ទុក និងកំណត់ពិរុទ្ធភាពលើជនជាប់ចោទ សុំតំកល់ការចោទប្រកាន់នៅដដែល និងសុំឱ្យផ្តន្ទាទោសជនលើតាមច្បាប់ ។

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ ឈ្មោះ[redacted]សន្និដ្ឋានថា កូនក្តីរបស់ខ្លួនពុំបានប្រព្រឹត្តអំពើប្លន់ដូចការចោទប្រកាន់ទេ ដោយសំអាងលើចម្លើយសាក្សីឈ្មោះ[redacted]ពិរុទ្ធជនដែលបានឆ្លើយនាពេលសវនាការ ថាចូលទៅយកទ្រព្យសម្បត្តិគេដោយស្រួលតែម្នាក់ឯង ពុំមានបក្សពួកនៅរងចាំមើលផ្លូវនិងពុំមានឈ្មោះ[redacted]នៅកន្លែងកើតហេតុ ពេលខ្លួនយករបស់គេហើយទើបជួបឈ្មោះនេះ

កំពុងជិះម៉ូតូម្នាក់ឯងតាមផ្លូវ ជាការសន្និដ្ឋានដោយមិនបានធ្វើការផ្គុំភស្តុតាង មិនអាចឱ្យពិចារណាបានឡើយ ព្រោះថា គ្រាន់តែវិភាគទៅលើមូលដ្ឋាននៃការប្រគល់ទ្រព្យសម្បត្តិ ដែលលួចបានដោយជនជាប់ចោទឈ្មោះ [redacted] ទៅជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] យកទៅលក់ គេអាចកំណត់បានថា ជនទាំងបីជាបក្សពួក មានផលប្រយោជន៍រួមដែលអាចទទួលផលនៃអំពើល្មើសច្បាប់ ការវិភាគនេះអាចទាញហេតុផលច្បាស់ថា នៅចំពោះមុខនគរបាលយុត្តិធម៌ ជាចម្លើយដែលឆ្លើយយ៉ាងត្រឹមត្រូវ តាមការប្រព្រឹត្តជាក់ស្តែងរបស់ជនជាប់ចោទទាំងអស់ ហើយក៏ជាភស្តុតាងដែលត្រូវទទួលយកមកធ្វើការវិនិច្ឆ័យសេចក្តីតាមផ្លូវច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១/ទទួលបណ្តឹងទាស់ ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០១០ របស់ឈ្មោះ [redacted] ហៅ [redacted] ដែលបានប្តឹងទាស់ និងសាលក្រមព្រហ្មទណ្ឌ កំបាំងមុខ លេខ ១៥៦.ក្រ២ ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុសនិងគតិច្បាប់ ។

២/តំកល់សាលក្រមព្រហ្មទណ្ឌ លេខ ១៥៦.ក្រ២ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូល ដដែល ។

៣/សាលក្រមនេះ ជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១០ ចំពោះមុខជនជាប់ ចោទឈ្មោះ [redacted]

បើកផ្លូវប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះទី២ |
|---|---|---|
| [redacted] | [redacted] [redacted] | [redacted] |



Scanned by CamScanner